# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

~~~~~~~~~

ក្រសួងមហាផ្ទៃ និងក្រសួងផែនការ

លេខ :...៩៩..............ប្រក

## ប្រកាសណែនាំអន្តរក្រសួង

### ស្តីពី

### ការប្រើប្រាស់សេចក្តីណែនាំពីដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងគំរូសៀវភៅផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ៥ឆ្នាំ (២០០៣-២០០៧) និងកម្មវិធីវិនិយោគឃុំ សង្កាត់ ៣ឆ្នាំ រំកិល (២០០៣-២០០៥)

### សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង រដ្ឋមន្ត្រីក្រសួងផែនការ

- អនុវត្តតាមខ្លឹមសារប្រការ៣០ នៃប្រកាសអន្តរក្រសួងមហាផ្ទៃ និងក្រសួងផែនការលេខ ០៩៨ ប្រក ចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ ឃុំ សង្កាត់

### សម្រេច

<u>ប្រការ ១</u>: ប្រកាសណែនាំនេះរៀបចំឡើងក្នុងគោលបំណងផ្តល់ជំនួយបច្ចេកទេស ដល់គណៈកម្មាធិការកសាងផែនការនិងថវិកាឃុំ សង្កាត់ ក្នុងការអនុវត្តន៍ការរៀបចំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ រយៈពេល ៥ឆ្នាំ (២០០៣-២០០៧) និងកម្មវិធីវិនិយោគ ៣ឆ្នាំរំកិល (២០០៣-២០០៥) ។

<u>ប្រការ២</u>: គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ សង្កាត់ និងគ្រប់អ្នកពាក់ព័ន្ធត្រូវធ្វើការរៀបចំ និងចូលរួមកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ រយៈពេល ៥ឆ្នាំ (២០០៣-២០០៧) និងកម្មវិធីវិនិយោគឃុំ សង្កាត់ ៣ឆ្នាំរំកិល (២០០៣-២០០៥) តាមខ្លឹមសារនៃសេចក្តីណែនាំស្តីពីដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធទី១ នៃប្រកាសណែនាំនេះ។

<u>ប្រការ៣</u>: គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ សង្កាត់ និងគ្រប់អ្នកពាក់ព័ន្ធត្រូវធ្វើការចងក្រងសៀវភៅផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ រយៈពេល ៥ឆ្នាំ (២០០៣-២០០៧ ) និងកម្មវិធីវិនិយោគឃុំ សង្កាត់
~~~~~~~~~

៣ឆ្នាំរំកិល (២០០៣-២០០៥ ) តាមខ្ទឹមសារទំរង់គំរូមាតិកា ដូចមានភ្ជាប់ជាឧបសម្ព័ន្ធទី២ នៃប្រកាសណែនាំនេះ ។

**ប្រការ៥:** ប្រកាសណែនាំនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី .. ខែ .. ឆ្នាំ ២០០២

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ — រដ្ឋមន្ត្រីក្រសួងផែនការ

ស ខេង — យូ ហុកគ្រី — ឆាយ-ថន

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-សមាជិក "គ.ឃ.ស"
" ដើម្បីជូនជ្រាប "
-សាលាខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
"ដើម្បីមុខការ"